# The Decline of the Great Tonle Sap Snake Hunt

THURSDAY, AUGUST 9, 2007

BY JEREMY GANTZ
AND LOR CHANDARA
THE CAMBODIA DAILY

EK PHNOM DISTRICT, Battambang province - When fish became scarce in his corner of the sprawling Tonle Sap, Ly Pov did what thousands of others barely surviving in the lake's floating villages do: He joined the world's largest snake hunt, putting his worn fishing nets to a lucrative new use in the flooded forests ringing the lake.

But today, two years after he joined the monsoon season hunt—which annually pulls an estimated 7 million water snakes from Southeast Asia's largest lake—Ly Pov's daily haul is a fraction of what it once was, falling from a daily average of 50 kg to just 15 kg.

That signals trouble for the famously fertile Tonle Sap.

Snake hunting became increasingly popular in the last two decades, as the number of fish in the lake declined, according to Sharon Brooks, a doctoral student in biological sciences at the University of East Anglia in England who has been studying the snake hunt and market for the last three years.

Seven of the lake's estimated 14 snake species, including the endemic Tonle Sap water snake, started being sold as an inexpensive alternative to fish, primarily as crocodile food for the hundreds of crocodile farms around the lake, but also as food for people.

"The fact that [water snakes] are so abundant across the Tonle Sap, occupying so many ecological niches, makes it likely that their overharvesting will have a profound negative impact on the ecology of the lake," said Joe Walston, country director for the Wildlife Conservation Society, which is working with the Ministry of Environment to develop government policies to manage the snake population.

But beyond observations of worried Tonle Sap fishermen, the government is unsure how rapidly each snake species is disappearing, and what would happen to the lake and its residents if they were to vanish. "At the moment we just don't know enough," Walston said.

Both Walston and Brooks said they believed the number of snakes collected annually on the Tonle Sap to be larger than any other snake hunt in the world. At the present time, at least half of the 15,000 households living on the lake rely on snake hunting for income, Brooks wrote by e-mail.

"Everything about this system—from the hydrology of the lake and the abundance of snakes, to the trade dynamics and markets—is unique," she added.

But Brooks fears that the snake hunt is unsustainable, with the average snake catch per fisherman declining by approximately 70 percent in recent years. And if the water snake is hunted into oblivion, the effect could be devastating both for the lake and its residents, she said.

The most abundant species, such as the rainbow water snake, which forms 70 percent of hunters' annual catch, are an important food source for large water birds—many of which are endangered, Brooks said.

"We can't really say what would happen if the snakes disappeared, ty," Brooks said. balance of the lake has already been severely disrupted, but it is likely to be quite profound due to the loss of biodiversi-

Next year, the government plans to conduct its own research to corroborate Brooks' findings, and to develop a management plan to nurse the snake population back to health, said Heng Savannara of the Ministry of Agriculture's Fisheries Administration.

"If Cambodia has good management of the water snakes, we think that there's still potential for plenty of snake hunting," he added.

Policy options could include creating a hunting off-season, banning some hunting methods, placing certain species on a Protected Species list, or creating additional government-protected wildlife sanctuaries, Walston said.

But writing policies may be easier than enforcing them. Banning snake hunting in the Prek Toal Core Area, one of the lake's three wildlife sanctuaries, has not stabilized the local water snake population, said Ly Son, head of the protected area's tourism office.

"The snakes are decreasing every year," he said last week in his floating office in Prek Toal village. "It's very difficult to control the hunt.... It's still anarchy."

Walston believes that it will be virtually impossible for provincial authorities to enforce any new snake-hunt regulations.

And with crocodile farms buying snakes despite the industry downturn, it seems unlikely that the thousands of snake hunters plying the Tonle Sap's waters will be able to pass up profit anytime soon.

For Ly Pov, 31, snake hunting is a matter of survival. Asked at his Prek Toal village home what he would do during the wet season if the Tonle Sap's snakes disappeared altogether, he had a simple answer: "Nothing."

# ការធ្លាក់ចុះពីការប្រមាញ់សត្វពស់នៅក្នុង បឹងទន្លេសាប

ដោយ Jermy Gantz និង ខ្យា ចាន់ដារ៉ា
THE CAMBODIA DAILY

ស្រុកឯកភ្នំ, ខេត្តបាត់ដំបង - នៅពេលត្រីកាន់តែក្រទៅនៅក្នុងមួយជ្រុងនៃបឹងទន្លេសាបមុំផ្ទះគាត់នោះ លី ពៅ បានធ្វើអ្វីដែលមនុស្សរាប់ពាន់នាក់ផ្សេងទៀតត្រឹមតែបានមួយរស់នៅក្នុងភូមិបណ្តែតទឹកនៅក្នុងបឹងនេះធ្វើ គឺថា គាត់បានចូលរួមក្នុងការប្រមាញ់ដ៏ធំបំផុតលើពិភពលោករកចាប់សត្វពស់ដោយរាយមងរហែករយៃរបស់គាត់តាមរបៀបថ្មីដែលអាចរកចំណូលបានច្រើននៅក្នុងព្រៃលិចទឹកព័ទ្ធជុំវិញបឹងនេះ ។

ប៉ុន្តែពេលនេះ រយៈពេលពីរឆ្នាំក្រោយពីគាត់បានចូលរួមចាប់ពស់នៅរដូវមូសុងដែលជារៀងរាល់ឆ្នាំ ចាប់យកបានពស់៧ លានក្បាលពីបឹងដ៏ធំបំផុតនេះនៅអាស៊ីអាគ្នេយ៍ ការចាប់ពស់រាល់ថ្ងៃរបស់ លី ពៅ គឺចាប់បានតែមួយផ្នែកតូចនៃចំនួនដែលធ្លាប់តែចាប់បានគឺធ្លាក់ពីមួយថ្ងៃជាមធ្យមពី៥០គីឡូក្រាមមកត្រឹម១៥គីឡូក្រាមប៉ុណ្ណោះ ។

នោះគឺផ្តល់សញ្ញាថាមានបញ្ហាហើយចំពោះទន្លេសាបដែលមានជីជាតិបំផុតនេះ ។

យោងតាមលោកស្រី សារ៉ុន ប្រ៊ូក និស្សិតថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រជីវវិទ្យា នៅសាកលវិទ្យាល័យ អង់គ្លីយ៉ាភាគខាងកើតក្នុងប្រទេសអង់គ្លេសដែលបាននិងកំពុងសិក្សាការចាប់ពស់និងទីផ្សាររយៈពេលបីឆ្នាំមកនេះ បានអោយដឹងថា ការចាប់ពស់កាន់តែពេញនិយមក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ពីព្រោះចំនួនត្រីក្នុងបឹងនេះបានធ្លាក់ចុះ ។ សត្វពស់៧ប្រភេទចំណោមសត្វពស់ប្រមាណ១៤ប្រភេទនៅក្នុងបឹងនេះរួមទាំងពស់ទឹកក្នុងតំបន់ទន្លេសាប ត្រូវគេចាប់ផ្តើមលក់ថោកៗជំនួសត្រី ដែលដំបូងគឺធ្វើជាអាហារសំរាប់សត្វក្រពើស៊ីអោយកសិដ្ឋានចិញ្ចឹមសត្វក្រពើរាប់រយកន្លែងនៅជុំវិញបឹងនេះ ប៉ុន្តែក៏ជាអាហារសំរាប់មនុស្សដែរ ។

លោក ហ្ស៊ូ វ៉ាល់ស្តូន នាយកនៃអង្គការសង្គមអភិរក្សសត្វព្រៃដែលកំពុងធ្វើការជាមួយក្រសួងបរិស្ថានដើម្បីអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងចំនួនសត្វពស់ បានមានប្រសាសន៍ថា "ហេតុដែលពស់ទឹកសំបូរបំផុតនៅទន្លេសាបដែលមានស្ថានភាពបរិស្ថានយ៉ាងច្រើនបំផុត ធ្វើអោយវាទំនងជាថា ការចាប់សត្វពស់ហួសកំរិតរបស់ពួកគេ និងមានឥទ្ធិពលអវិជ្ជមានយ៉ាងជ្រៅមួយទៅលើបរិស្ថាននៃបឹងនេះ" ។

ប៉ុន្តែក្រៅពីការអង្កេតពីអ្នកនេសាទនៅទន្លេសាបដែលគេព្រួយបារម្ភ រដ្ឋាភិបាលមិនច្បាស់ថាតើរាល់ចំពូកសត្វពស់កំពុងបាត់បង់ដោយឆាប់រហ័សរបៀបណា ហើយអ្វីនឹងកើតឡើងចំពោះបឹងនិងអ្នកស្រុកនៅក្នុងបឹងនេះ ប្រសិនបើសត្វនេះសាបសូន្យ ។ លោក វ៉ាល់ស្តូន និងលោកស្រី ប្រ៊ូក បាននិយាយថា ពួកគេជឿថាចំនួនសត្វពស់ដែលគេប្រមូលបានប្រចាំឆ្នាំនៅទន្លេសាបមានចំនួនច្រើនជាងការចាប់ពស់ផ្សេងទៀតក្នុងពិភពលោក ។ លោកស្រី ប្រ៊ូក បានសរសេរតាមអ៊ីមេលថា បច្ចុប្បន្ននេះ អ្នកស្រុកយ៉ាងហោចពាក់កណ្តាលចំណោមអ្នកស្រុក១៥.០០០នាក់ដែលរស់នៅលើបឹងនេះ ពឹងផ្អែកលើការចាប់ពស់ដើម្បីប្រាក់ចំណូល ។

លោកស្រីបានបន្ថែមថា "អ្វីៗអំពីប្រព័ន្ធនេះមកពីធារាសាស្ត្រនៃបឹងនេះនិងភាពសំបូរនៃសត្វពស់រហូតដល់កំលាំងចលករពាណិជ្ជកម្មនិងទីផ្សារ គឺមានសភាពប្លែក ។

ប៉ុន្តែលោកស្រី ប្រ៊ូក ខ្លាចថា ការចាប់សត្វពស់ គឺមិនស្ថិតស្ថេរទេ ដោយការចាប់ពស់ជាមធ្យមសំរាប់អ្នកនេសាទម្នាក់ធ្លាក់ចុះប្រមាណ៧០ភាគរយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។ លោកស្រីបានមានប្រសាសន៍ថា ហើយប្រសិនបើពស់ទឹក ត្រូវបានចាប់ដោយគ្មាននរណាចាប់ភ្លឹក ផលប៉ះពាល់អាចជាការបំផ្លាញបឹងនិងអ្នកស្រុក ។

លោកស្រី ប្រ៊ូក បានមានប្រសាសន៍ថា ប្រភេទសត្វដែលសម្បូរបំផុតនេះ ដូចជាពស់ព្រលិតដែលមានចំនួន៧០%នៃចំនួនដែលអ្នកប្រមាញ់ចាប់បានរាល់ឆ្នាំនោះ គឺជាប្រភពចំណីដ៏សំខាន់នៃសត្វស្លាបទឹកធំៗដែលភាគច្រើនជិតផុតពូជទៅហើយ ។

លោកស្រី ប្រ៊ូក បានមានប្រសាសន៍ថា "យើងពិតជាមិនអាចនិយាយថាអ្វីនឹងកើតឡើង ប្រសិនបើសត្វពស់សាបសូន្យនោះ ជាពិសេសខណៈដែលតុល្យភាពនៃបឹងនេះត្រូវបានបង្អាក់ធ្ងន់ធ្ងររួចជាស្រេច ប៉ុន្តែវាទំនងជាជ្រៅបំផុតដោយសារតែការបាត់បង់ជីវចំរុះ" ។

លោក ហេង សុវណ្ណារ៉ា ធ្វើការនៅរដ្ឋបាលជលផលនៃក្រសួងកសិកម្មបានមានប្រសាសន៍ថា នៅឆ្នាំក្រោយ រដ្ឋាភិបាលមានផែនការធ្វើការស្រាវជ្រាវដោយផ្ទាល់ដើម្បីបញ្ជាក់លទ្ធផលរបស់លោកស្រី ប្រ៊ូក និងដើម្បីអភិវឌ្ឍផែនការគ្រប់គ្រងមួយធ្វើអោយចំនួនសត្វពស់មានច្រើនឡើងៗ ។

លោកបានមានប្រសាសន៍បន្ថែមថា "ប្រសិនបើកម្ពុជាមានការគ្រប់គ្រងល្អនូវពស់ទឹក យើងគិតថា នៅតែមានសក្តានុពលចំពោះការចាប់ពស់ដ៏ច្រើន" ។

លោក វ៉ាល់ស្តូន បានមានប្រសាសន៍ថា ជំរើសនយោបាយអាចរាប់បញ្ចូលការបង្កើតការហាមចាប់ពស់ខុសរដូវ ការហាមប្រាមឧបករណ៍ចាប់ពស់ ដាក់ចំពូកសត្វមួយចំនួននៅលើបញ្ជីចំពូកសត្វដែលគេការពារឬក៏បង្កើតជំរកសត្វព្រៃការពារដោយរដ្ឋាភិបាលបន្ថែមទៀត ។

លោក លី សុន ប្រធានការិយាល័យទេសចរណ៍នៅតំបន់ការពារនេះបានមានប្រសាសន៍ថា ប៉ុន្តែការសរសេរនយោបាយប្រហែលជាងាយស្រួលជាងការអនុវត្តវា ។ ការហាមប្រាមមិនអោយចាប់សត្វពស់នៅក្នុងតំបន់ស្នូលព្រែកទាល់ ដែលជាជំរកសត្វព្រៃមួយចំណោមជំរកសត្វព្រៃពាកន្លែងនៅក្នុងបឹងនេះ មិនមានស្ថិរភាពសំរាប់សត្វពស់ទឹកក្នុងស្រុកទេ ។

លោកបានមានប្រសាសន៍កាលពីសប្តាហ៍មុននៅក្នុងការិយាល័យបណ្តែតទឹករបស់លោកនៅក្នុងភូមិព្រែកទាល់ថា "សត្វពស់ចុះថយរៀងរាល់ឆ្នាំ ។ វាជាការពិបាកណាស់ដើម្បីត្រួតពិនិត្យការប្រមាញ់នេះ... ។ វានៅតែអនាធិបតេយ្យ" ។

លោក វ៉ាល់ស្តូន ជឿថា វាសឹងតែនឹងមិនអាចទេសំរាប់អាជ្ញាធរខេត្តដើម្បីអនុវត្តបទបញ្ជាចាប់ពស់ថ្មីណាមួយនោះ ។

ជាមួយនឹងកសិដ្ឋានចិញ្ចឹមក្រពើដែលទិញពស់ ថ្វីបើឧស្សាហកម្មនេះចុះថយក៏ដោយ វាមិនទំនងថា អ្នកចាប់ពស់រាប់ពាន់នាក់ដែលឆ្លងកាត់ទឹកទន្លេសាប នឹងអាចឆ្លៀតយកផលចំណេញបាននៅពេលណាមួយឆាប់ៗនេះទេ ។ សំរាប់ លី ពៅ អាយុ៣១ឆ្នាំ វិញការចាប់ពស់គឺសំរាប់តែមួយរស់ទេ ។ ដោយត្រូវបានសួរនៅឯផ្ទះរបស់គាត់ក្នុងភូមិព្រែកទាល់នូវអ្វីដែលគាត់ធ្វើ អំឡុងរដូវភ្លៀងប្រសិនបើសត្វពស់នៅទន្លេសាបសាបសូន្យទាំងអស់នោះ គាត់បានឆ្លើយធម្មតាថា "គ្មានទេ" ។G